00746180



# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហព្រះរាជអាជ្ញា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Oct-2011, 13:23
CMS/CFO: Phok Chanthan

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ : **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាតបរួមរបស់សហព្រះរាជអាជ្ញា ចំពោះ "សំណើសុំរបស់ លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង និងញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ គាំទ្រសំណើមួយផ្នែករបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង"**

---

| ដាក់ដោយ៖ | ផ្ញើជូន៖ | ចម្លងជូន៖ |
|---|---|---|
| **សហព្រះរាជអាជ្ញា៖** | **អង្គជំនុំជម្រះសាលាដំបូង៖** | **ជនជាប់ចោទ៖** |
| ជា លាង | ចៅក្រម **និល ណុន** ជាប្រធាន | អៀង សារី |
| Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង ធីរិទ្ធ |
| | ចៅក្រម **យ៉ា សុខន** | នួន ជា |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |

ចៅក្រម **យូរ ឧត្តរា**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់៖**

**មេធាវីការពារក្តី៖**

អាង ឧត្តម

Michael G. KARNAVAS

ផាត់ ពៅស៊ាង

Diana ELLIS

សុន អរុណ

Michiel PESTMAN

Victor KOPPE

សរ សូវ៉ាន

Jacques VERGÈS

Original EN: 00743947-00743959

## I. សេចក្ដីផ្ដើម

១. នៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដីលោក អៀង សារី បានដាក់ *សំណើរបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង* ("សំណើសុំរបស់ លោក អៀង សារី")[1]។ ក្រុមមេធាវីការពារក្ដីលើកជាទឡ្ហីករណ៍ថា "នៅក្នុងសំណុំរឿង មានឯកសារសម្ងាត់បំផុតជាង ៥000 ឯកសារ" ដែលក្រុមមេធាវីការពារក្ដីមិនមានលទ្ធភាពពិនិត្យមើលបាន ដែលស្ថានភាពបែបនេះនឹង "រំលោភលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី" ហើយថា "ការលាតត្រដាងត្រឹមតែចំណងជើងទូទៅនៃឯកសារសម្ងាត់បំផុតទាំងនោះ" នឹង "មិនគ្រប់គ្រាន់ក្នុងការទប់ស្កាត់ការប៉ះពាល់លើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អៀង សារី ឡើយ"[2]។ ក្រុមមេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង អនុញ្ញាតឱ្យក្រុមមេធាវីការពារក្ដីអាចពិនិត្យមើលរាល់ឯកសារសម្ងាត់បំផុតទាំងនោះ។ ជាជម្រើសមួយផ្សេង ក្រុមមេធាវីការពារក្ដីស្នើសុំដោយសមហេតុផលជាងនេះ ឱ្យអង្គជំនុំជម្រះសាលាដំបូង "ពិនិត្យឯកសារសម្ងាត់បំផុតទាំងនេះដែលមាននៅក្នុងសំណុំរឿង *ជាអសាធារណៈ* ឡើងវិញ ដើម្បីសម្រេចថាតើឯកសារណាខ្លះ (ប្រសិនបើមាន) គួរលាតត្រដាងឱ្យក្រុមមេធាវីការពារក្ដីបានដឹង ហើយឯកសារណាខ្លះដែលត្រូវបដិសេធមិនទទួលយកធ្វើជាភស្តុតាង ឬយកមកធ្វើជាសំអាងចំពោះឯកសារសម្ងាត់បំផុតទាំងឡាយណា ដែលមិនត្រូវបានលាតត្រដាងឱ្យក្រុមមេធាវីការពារក្ដី"[3]។

២. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ក្រុមមេធាវីការពារក្ដីរបស់ អ្នកស្រី អៀង ធីរិទ្ធ បានដាក់ញត្តិមួយ ("ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ") ដែលគាំទ្រផ្នែកខ្លះៗនៃសំណើសុំរបស់ លោក អៀង សារី ប៉ុន្តែកំហិតសំណើសុំការលាតត្រដាងឯកសារឱ្យមកត្រឹមតែ (ក) ឯកសារភស្តុតាងពាក់ព័ន្ធទៅនឹងជនរងគ្រោះ ដែលនឹងចូលរួមនៅក្នុងការជំនុំជម្រះក្ដីក្នុងនាមពួកគាត់ជាសាក្សី ឬជាដើមបណ្ដឹងរដ្ឋប្បវេណី និង (ខ) ភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកនានា ដែលមាននៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿង[4]។

---

[1] ឯកសារ E118, សំណើរបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ (យោងនៅក្នុងនេះថាជា "សំណើរបស់លោក អៀង សារី")។

[2] ឯកសារ E118, សំណើរបស់លោក អៀង សារី, ត្រង់ទំព័រ ១។

[3] ឯកសារ E118, សំណើរបស់លោក អៀង សារី, ត្រង់ទំព័រ ៦-៧។

[4] ឯកសារ E118/1, ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ គាំទ្រសំណើមួយផ្នែករបស់លោក អៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុត, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, កថាខណ្ឌ ៣-៥ ["ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ"]។

៣. សហព្រះរាជអាជ្ញាសូមដាក់សារណាតបរួមរបស់ខ្លួនមួយនេះ ទៅកាន់សំណើសុំរបស់ លោក អៀង សារី និងញត្តិរបស់ អ្នកស្រី អៀង ធីរិទ្ធ។ សារណាតបនេះស្ថិតនៅក្នុងកាលបរិច្ឆេទកំណត់ ដែលមានចែងនៅក្នុងមាត្រា ៨ (៣) នៃសេចក្តីណែនាំអនុវត្ត[5]។

៤. ពាក់ព័ន្ធទៅនឹងសំណើសុំរបស់ លោក អៀង សារី សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងច្រានចោលសំណើសុំរបស់ លោក អៀង សារី ដោយហេតុថាសំណើនេះ ស្នើសុំឱ្យក្រុមមេធាវីការពារក្តីអាចពិនិត្យបានជាស្វ័យប្រវត្តិនូវ*គ្រប់* ឯកសារសម្ងាត់បំផុត*ទាំងអស់* ដែលមាននៅក្នុងសំណុំរឿង។ សហព្រះរាជអាជ្ញាសូមលើកឡើងដូចតទៅ៖ (ក) សំណើសុំនេះមិនត្រូវបានគាំទ្រដោយការវិភាគណាមួយទៅលើលក្ខណៈនៃឯកសារ ដែលត្រូវបានចាត់ប្រភេទថាជាឯកសារសម្ងាត់បំផុតនោះទេ ហើយហេតុដូច្នេះ សំណើសុំនេះមិនមានភាពត្រឹមត្រូវ ឬមិនច្បាស់លាស់ដែលមិនអាចទទួលយកបាន (ខ) យ៉ាងហោចណាស់ ៩៧% នៃឯកសារដែលមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធឯកសារ E118.1.1 នៃសំណើសុំរបស់ លោក អៀង សារី មិនមានលក្ខណៈជាភស្តុតាង (២៦,៧%) ឬជាគោលការណ៍ គឺជាឯកសារភស្តុតាង ដែលត្រូវបានចាត់ប្រភេទថា "សម្ងាត់បំផុត" ទៅតាមលក្ខខណ្ឌនៃមាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ[6] (៧០,៦%) (គ) ចំពោះភស្តុតាងដែលជាកម្មវត្ថុនៃវិធានការការពារ ដែលបានសម្រេចដោយ ក.ស.ច.ស សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការពិនិត្យឡើងវិញទៅលើសេចក្តីសម្រេចទាំងនោះ ហើយប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលវិធានការការពារទាំងនោះ សហព្រះរាជអាជ្ញាសូមស្នើសុំថាឯកសារដែលពាក់ព័ន្ធនានា គួរត្រូវចាត់ប្រភេទឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង។ ក្នុងករណី

[5] សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការដាក់ឯកសារចំពោះមុខ អ.វ.ត.ក, អ.វ.ត.ក/០១/២០០៧/ វិសោធនកម្មលើកទី ៧, ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១១។ សំណើរបស់លោក អៀង សារី (E118) ត្រូវបានដាក់ និងជូនដំណឹងនៅថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១។ រយៈពេលដប់ថ្ងៃសម្រាប់ដាក់សារណាតបនេះ បានចាប់ផ្តើមនៅថ្ងៃទី ១៥ ខែ កញ្ញា និងបញ្ចប់នៅថ្ងៃ សៅរ៍ ទី ២៦ ខែ កញ្ញា ឆ្នាំ២០១១។ តាមរយៈសេចក្តីសម្រេចរបស់ខ្លួន ឯកសារ E120 ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនតំណឹងដល់ភាគីថា ខ្លួននឹងឈប់សម្រាកនៅក្នុងអំឡុងបុណ្យភ្ជុំបិណ្ឌ ហើយថាប្រសិនបើពេលវេលាកំណត់ណាមួយត្រូវនឹងថ្ងៃឈប់សម្រាកនេះ កាលបរិច្ឆេទកំណត់សម្រាប់ដាក់ឯកសារ នឹងជាថ្ងៃ ច័ន្ទ ទី ០៣ ខែ តុលា ឆ្នាំ ២០១១។ ញត្តិរបស់លោកស្រី អៀង ធីរិទ្ធ (ឯកសារលេខ E118/1) ត្រូវបានជូនដំណឹងដល់ ក.ស.ព នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

[6] សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការចាត់ប្រភេទឯកសារ និងការគ្រប់គ្រងព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿង អវតក/០០៤/២០០៩ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩ ("សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ")។

ដែលអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតតាមសំណើសុំនេះ សហព្រះរាជអាជ្ញាសូមលើកឡើងថា ឯកសារសម្ងាត់បំផុតនានា គួរត្រូវបានបង្កើតជាឯកសារសម្ងាត់ដោយមានកោសលុប ហើយលាតត្រដាងដល់ភាគីទាំងអស់បានដឹង។ (ឃ) មិនមានការរំលោភបំពានលើគោលការណ៍សមភាពក្នុងរឿងក្ដីនោះទេ ដោយហេតុថាសហព្រះរាជអាជ្ញាក៏មិនអាចពិនិត្យមើលឯកសារសម្ងាត់បំផុតណាមួយបានដែរ លើកលែងតែឯកសារនោះ គឺជាឯកសារដែលព្រះរាជអាជ្ញាដាក់ដោយខ្លួនឯង។ (ង) សហព្រះរាជអាជ្ញា យល់ស្របជាមួយនឹងក្រុមមេធាវីការពារក្ដី ចំពោះភាពចាំបាច់ក្នុងការកែប្រែតារាងផ្នែកឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿង ដើម្បីអាចដាក់ចំណងជើង (ដោយមានការកោសលុបប្រសិនបើចាំបាច់) សម្រាប់គ្រប់ឯកសារទាំងអស់បាន។

៥. ពាក់ព័ន្ធទៅនឹងញត្តិរបស់ អ្នកស្រី អៀង ធីរិទ្ធ សហព្រះរាជអាជ្ញាសង្កេតឃើញថា ញត្តិនេះមិនបានប្រមើលមើលថា គ្រប់ជនរងគ្រោះទាំងអស់ ដែលឯកសាររបស់ពួកគាត់មាននៅក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿងនោះ សុទ្ធតែបានស្នើសុំយ៉ាងមានប្រសិទ្ធភាពឱ្យមានវិធានការការពារនោះទេ។ សហព្រះរាជអាជ្ញាសូមស្នើសុំថា មុននឹងលាតត្រដាងឯកសាររបស់ជនរងគ្រោះទាំងនេះ អង្គជំនុំជម្រះគួរចេញសេចក្ដីសម្រេចស្ដីពីវិធានការការពារ និងចាត់វិធានការកោសលុបសម្ភារៈណាដែលអាចត្រូវបានប្រើប្រាស់ដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ ឬក្រុមគ្រួសាររបស់ជនរងគ្រោះពាក់ព័ន្ធណាមួយបាន។ សហព្រះរាជអាជ្ញាយល់ស្របទៅនឹងក្រុមមេធាវីការក្ដីរបស់ អ្នកស្រី អៀង ធីរិទ្ធ ដែលថាជាគោលការណ៍ កំណត់ហេតុវេជ្ជសាស្ត្រ និងសម្ភារៈពាក់ព័ន្ធនានាដទៃទៀត ត្រូវចាត់ប្រភេទថាជា "ឯកសារសម្ងាត់បំផុត" លើកលែងតែមានអង្គជំនុំជម្រះសាលាដំបូងសម្រេចផ្សេងពីនេះ[7]។

## II. ច្បាប់ជាធរមាន

៦. មាត្រា ៣១៩ (ស្ដីអំពីការពិនិត្យមើលសំណុំរឿង) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ចែងថា "មុនពេលសវនាការ មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ..." ហើយ "អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឱ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី"។

៧. វិធាន ៨៦ (ស្ដីអំពីការមើលសំណុំរឿង) នៃវិធានផ្ទៃក្នុង ចែងថា៖

[7] ឯកសារ **E118/1**, ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ, កថាខណ្ឌ ៧។

នៅគ្រប់ពេលវេលា សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគីទាំងអស់ ត្រូវមានសិទ្ធិពិនិត្យមើល និងថតចម្លងសំណុំរឿង ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង នៅពេលម៉ោងធ្វើការ និងត្រូវគោរពទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ដំណើរការល្អរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

៨. មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធាន ៨៦ នៃវិធានផ្ទៃក្នុង ត្រូវបានកំហិតដោយបទប្បញ្ញត្តិជាធរមានរបស់ អ.វ.ត.ក ពាក់ព័ន្ធទៅនឹងកម្រិតនៃការសម្ងាត់របស់ឯកសារ និងព័ត៌មាន។ សេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ ចែងអំពីសេចក្តីណែនាំចំពោះការចាត់ប្រភេទឯកសារថា "សម្ងាត់បំផុត" ដោយចៅក្រម ឬអង្គជំនុំជម្រះដែលពាក់ព័ន្ធ។ មាត្រា ២ (ឃ) (iii) នៃសេចក្តីណែនាំអនុវត្តនេះ រៀបរាប់លម្អិតអំពីកម្រិតនៃការសម្ងាត់ និងផ្តល់ជានិយមន័យនៃពាក្យ "សម្ងាត់បំផុត" ថា "បើកចំហជូនចំពោះតែចៅក្រម បុគ្គលផ្សេងទៀត ដែលរួមមានបុគ្គលិកតុលាការ ដែលត្រូវការពិនិត្យមើលឯកសារ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន ប៉ុន្តែសិទ្ធិមើលឯកសារត្រូវទទួលបានសេចក្តីសម្រេចពីតុលាការជាមុន"។ ផ្ទុយពីការអះអាងរបស់លោក អៀង សារី[8] ពាក្យថា "បុគ្គលិកតុលាការ" មិនបានរួមបញ្ចូលទាំងសមាជិកក្រុមមេធាវីការពារក្តី (ឬភាគីដទៃទៀត) ឡើយ។ ពាក្យនេះគឺកំហិតត្រឹមតែបុគ្គលិករបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តែប៉ុណ្ណោះ ដូចបានកំណត់នៅក្នុងមាត្រា ២ (ក) និង (ខ)។

៩. មាត្រា ៦ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ រៀបរាប់យ៉ាងជាក់លាក់អំពីឯកសារសម្ងាត់បំផុតនៃសំណុំរឿង ដែលមានខ្លឹមសារដូចតទៅ៖

> ជាគោលការណ៍ ឯកសារ និងព័ត៌មាន ក្នុងចំណាត់ថ្នាក់ដូចខាងក្រោម ជាឯកសារ និងព័ត៌មានសម្ងាត់បំផុត លើកលែងតែមានចំណាត់ថ្នាក់ផ្សេងពីនេះ ដោយសេចក្តីសម្រេចរបស់តុលាការ។
>
> ក. សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ (ដែលរួមមានការវាយតម្លៃអំពីហានិភ័យរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ)។
>
> ខ. ឯកសារ និងព័ត៌មាន ដែលទាក់ទងនឹងវិធានការការពារ។ និង
>
> គ. ព័ត៌មានដែលទាក់ទងទៅនឹងសុខភាពរបស់ជនសង្ស័យ ជនត្រូវចោទ និងជនជាប់ចោទ។

១០. បើទោះជាមិនត្រូវបានយោងដោយក្រុមមេធាវីការពារក្តីក៏ដោយ មាត្រា ៧.៣ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ ចែងថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ដែលម្ចាស់

---

[8] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, កថាខណ្ឌ ៤។

ពាក្យសុំក៏ជាកម្មវត្ថុនៃសំណើសុំវិធានការការពារផងដែរនោះ នឹងត្រូវចាត់ទុកថាជាឯកសារសម្ងាត់បំផុត លុះត្រាណាមានសេចក្តីសម្រេចលើសំណើសុំវិធានការការពារ។ មាត្រា ៩ នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ បញ្ជាក់បន្ថែមថា ឯកសារ ឬព័ត៌មាន អាចត្រូវបានចាត់ប្រភេទឡើងវិញបាន តែនៅក្នុងដំណាក់កាលជំនុំជម្រះក្តីតែប៉ុណ្ណោះ ដោយអនុលោមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង។ ម្យ៉ាងវិញទៀត មាត្រា ១០ (គ) ចែងថា បញ្ជីសារពើភ័ណ្ឌនៃផ្នែកសម្ងាត់បំផុតនៃសំណុំរឿង ត្រូវមានចំណងជើងឯកសារទាំងអស់នៅក្នុងសំណុំរឿង។

១១. មាត្រា ៣.១២ ដល់ ៣.១៥ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[9] ចែងអំពីនីតិវិធី ដែលភាគីដាក់ឯកសារអាចស្នើសុំការចាត់ប្រភេទឯកសាររបស់ខ្លួន និងអំពីនីតិវិធី ដែលអង្គជំនុំជម្រះពាក់ព័ន្ធ អាចសម្រេចពីភាពសមស្របនៃការចាត់ប្រភេទឯកសារ ដែលបានស្នើឡើង។

១២. វិធានការការពារមានចែងនៅក្នុងវិធាន ២៩ នៃវិធានផ្ទៃក្នុង និងនៅក្នុងសេចក្តីណែនាំអនុវត្តស្តីពីវិធានការការពារ[10]។ វិធាន ២៩ (៣) និង (៤) ចែងថា៖

> ៣. តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ឬតាមពាក្យសុំ និងក្រោយពេលពិគ្រោះយោបល់ជាមួយអង្គភាពគាំពារជនរងគ្រោះ ឬអង្គភាពគាំពារសាក្សី និងអ្នកជំនាញ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចាត់វិធានការសមស្រប ដើម្បីការពារ អ្នកប្តឹង ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលមកបង្ហាញខ្លួន ប្រសិនបើការបង្ហាញខ្លួននោះអាចធ្វើឱ្យអាយុជីវិត សុខមាលភាព ឬក្រុមគ្រួសារ ឬញាតិជិតស្និទ្ធរបស់ពួកគេ ត្រូវស្ថិតក្នុងសភាពគ្រោះថ្នាក់ធ្ងន់ធ្ងរ។ សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ អាចចេញដីកាបែបនេះ តាមការផ្តួចផ្តើមគំនិតរបស់ខ្លួន ក្នុងករណីដែលមានការបង្ហាញអំពីហានិភ័យបែបនេះនៅក្នុងសំណុំរឿង...
>
> ៤. ក្នុងបរិបទនេះ សហចៅក្រមស៊ើបអង្កេត និងអង្គជំនុំជម្រះ អាចចេញសេចក្តីបង្គាប់ដោយមានសំអាងហេតុចាត់វិធានការដើម្បីការពារអត្តសញ្ញាណជនទាំងនោះ ដូចជា៖
>
> ក. កំណត់យកអាសយដ្ឋានរបស់មេធាវីរបស់ពួកគេ ឬរបស់សមាគមនជនរងគ្រោះរបស់ពួកគេ ឬរបស់អង្គជំនុំជម្រះវិសាមញ្ញ ជាអាសយដ្ឋានទំនាក់ទំនងរបស់ពួកគេ តាមករណីសមស្រប។
>
> ខ. ប្រើរហស្សនាមនៅពេលនិយាយសំដៅទៅរកជនត្រូវការពារនោះ។

---

[9] សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីការដាក់ឯកសារ, អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី ៧, កែប្រែនៅថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០១១។

[10] សេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្តីពីវិធានការការពារ, អ.វ.ត.ក / ០៣/២០០៧/វិសោធនកម្មលើកទី ១, អនុម័តនៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨។

គ. អនុញ្ញាតឱ្យធ្វើកំណត់ហេតុស្ដួរយកចម្លើយរបស់ជននោះដោយមិនចាំបាច់សរសេរអត្ត-សញ្ញាណរបស់ជននោះ នៅក្នុងសំណុំរឿង។

ឃ. នៅពេលណាជនត្រូវចោទ ឬជនសង្ស័យស្នើឱ្យមានការឆ្លើយតទល់គ្នាជាមួយជននោះ គេអាចប្រើប្រាស់បច្ចេកទេសដែលអនុញ្ញាតឱ្យមានការចូលរួមពីចម្ងាយ ឬបំប្លែងសម្លេងដើម ឬបិទបាំងភិនភាគរបស់ជននោះ។

ង. ជាករណីលើកលែងចំពោះគោលការណ៍សវនាការជាសាធារណៈ អង្គជំនុំជម្រះអាចរៀបចំផ្នែកដំណើរការនីតិវិធីណាមួយជាសម្ងាត់ ឬអនុញ្ញាតឱ្យបង្ហាញភស្តុតាងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ឬក៏ប្រើប្រាស់មធ្យោបាយពិសេសៗដទៃទៀត។

១៣. ដូចគ្នានេះដែរ មាត្រា ២ (៦) នៃសេចក្ដីណែនាំអនុវត្តស្ដីពីវិធានការការពារ ចែងថា៖

នៅពេលដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះចេញវិធានការការពារ រាល់ឯកសារដែលពាក់ព័ន្ធនឹងដីកានោះ ត្រូវធ្វើកំណត់ត្រាទុកនៅក្នុងសំណុំឯកសារមួយដាច់ដោយឡែកពីសំណុំរឿង និងត្រូវគ្រប់គ្រងដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ តាមករណីសមស្រប។ ការពិនិត្យមើលសំណុំឯកសារនេះ ត្រូវទទួលការអនុញ្ញាតជាមុនពីសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ[11]។

## III. **ទឡ្ហីករណ៍**

## ក. ទឡ្ហីករណ៍របស់ក្រុមមេធាវីការពារក្ដី លោក អៀង សារី មិនត្រឹមត្រូវ មិនច្បាស់លាស់ ដែលមិនអាចទទួលយកបាន ពាក់ព័ន្ធនឹងប្រភេទឯកសារសម្ងាត់បំផុតដែលខ្លួនស្នើសុំដើម្បីពិនិត្យ និងមិនមានមូលដ្ឋានច្បាប់ត្រឹមត្រូវ

១៤. ក្រុមមេធាវីការពារក្ដីរបស់ លោក អៀង សារី លើកទឡ្ហីករណ៍ដោយមិនច្បាស់លាស់ថា "ឯកសារចំនួនជាង ៥០០០" ត្រូវបានចាត់ប្រភេទនាពេលបច្ចុប្បន្ននេះថា សម្ងាត់បំផុត[12]។ សូម្បីតែការពិនិត្យត្រួសៗទៅលើឯកសារដែលត្រូវបានកំណត់ថាសម្ងាត់បំផុតនៅក្នុងសារពើភ័ណ្ឌនៃសំណុំរឿង ក៏អាចឱ្យក្រុមមេធាវីការពារក្ដីសន្និដ្ឋានបានថា ក្នុងចំណោមឯកសារចំនួន ៥.២២០ នៅក្នុងសារពើភ័ណ្ឌនេះ

---

[11] សេចក្ដីណែនាំអនុវត្តរបស់ អ.វ.ត.ក ស្ដីពីវិធានការការពារ, អ.វ.ត.ក /០៣/២០០៧/វិសោធនកម្មលើកទី ១, មាត្រា ២.៦។

[12] ឯកសារ E118, សំណើរបស់លោក អៀង សារី, កថាខណ្ឌផ្ដើមនីតិវិធី (ទំព័រ ១), ក្នុងកថាខណ្ឌដដែល ១, ៦, ១០។

មានតែឯកសារចំនួន ៤.៤៣២ តែប៉ុណ្ណោះ ដែលជាឯកសារខុសៗគ្នា។ រីឯឯកសារចំនួន ៧៨៨ ទៀត គឺជាឯកសារបកប្រែ[13]។

១៥. ក្រុមមេធាវីការពារក្តីរបស់ លោក អៀង សារី ស្នើសុំការអនុញ្ញាតដើម្បីពិនិត្យមើល*គ្រប់* ឯកសារសម្ងាត់បំផុត*ទាំងអស់* ដែលមាននៅក្នុងសំណុំរឿង ដោយមិនមានការបែងចែក ឬមិនថាឯកសារទាំងនោះអាចនឹងត្រូវលើកយកមកបង្ហាញនៅក្នុងសវនាការនោះទេ[14]។ សំណើសុំបែបនេះ ខ្វះភាពជាក់លាក់គ្រប់គ្រាន់ មិនសមហេតុផល និងមិនមានមូលដ្ឋានច្បាប់ត្រឹមត្រូវ។ គ្រប់ភាគីទាំងអស់មានសិទ្ធិពិនិត្យមើលទាំងឯកសារសាធារណៈ និងឯកសារសម្ងាត់ រួមទាំងព័ត៌មានដែលមាននៅក្នុងសំណុំរឿងផងដែរ ហើយ ដូច្នេះ ភាគីមានសមត្ថភាពដើម្បីដឹងឮអំពីលក្ខណៈនៃឯកសារភាគច្រើនដែលត្រូវបានចាត់ប្រភេទថា "សម្ងាត់បំផុត" ដោយយោងទៅលើឯកសារដើមតាមរយៈលេខសម្គាល់ឯកសារជាក់លាក់ណាមួយ។ ខុសពីអ្វីដែលមានចែងនៅក្នុងមាត្រា ១០ (ខ) និង (គ) នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ វាជាការសោកស្តាយមួយដែលថា ព័ត៌មាននៅក្នុងបញ្ជីសារពើភ័ណ្ឌនៃសំណុំរឿង មិនបានបង្ហាញអំពីលក្ខណៈនៃឯកសារសម្ងាត់បំផុតឱ្យបានគ្រប់ពេលវេលានោះទេ ដោយហេតុថា មិនមានចំណងជើងឯកសារទាំងនោះ សូម្បីតែនៅក្នុងទម្រង់កោសលុប ឬទម្រង់ទូទៅក៏ដោយ (សូមមើល កថាខណ្ឌ ៣៦ ខាងក្រោម)។ ប៉ុន្តែ តាមការវិភាគត្រួសៗទៅលើបញ្ជីសារពើភ័ណ្ឌនោះ ក្រុមមេធាវីការពារក្តីអាចបែងចែងឯកសារ "សម្ងាត់បំផុត" ចេញជាពីរប្រភេទធំៗ៖ ឯកសារដែលមិនមានភាពពាក់ព័ន្ធទៅនឹងភស្តុតាង និងឯកសារដែលមាន ឬទំនងជាមានលក្ខណៈជាភស្តុតាង។

១៦. តាមរយៈការដាក់សំណើសុំដ៏ទូលំទូលាយបែបនេះ ដោយមិនមានធ្វើការវិភាគជាមូលដ្ឋានទៅលើលក្ខណៈនៃឯកសារសម្ងាត់បំផុតទាំងនោះជាមុនសិននោះ ក្រុមមេធាវីការពារក្តីរបស់ លោក អៀង សារី ដាក់បន្ទុកដោយមិនសមហេតុផល និងមិនចាំបាច់ លើអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀត។ ក្នុងន័យនេះ វាជាការចាំបាច់ដែលត្រូវកត់សម្គាល់ថា លោក អៀង សារី ខកខានមិនបានចង្អុលបង្ហាញទៅលើភស្តុតាង ឬប្រភេទឯកសារជាក់លាក់ណាមួយ ដែលគួរតែអាចឱ្យគាត់អាចពិនិត្យមើលបាន ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាននានានៃសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក ឡើយ។

---

[13] សូមមើលជាឧទាហរណ៍ ឯកសារ **A100/1, A209/I/1, B46, E9/4.3.1** មានទាំងបីភាសា។

[14] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, កថាខណ្ឌផ្តើមនីតិវិធី (ទំព័រ ១), ក្នុងកថាខណ្ឌដដែល ៤, ៦,៨ និងនៅក្នុងសេចក្តីសន្និដ្ឋានរបស់វា។

### ខ. អង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើសុំពិនិត្យមើលឯកសារសម្ងាត់បំផុត ដែលមិនមែនជាភស្តុតាង

១៧. ក្រុមមេធាវីការពារក្តីរបស់ លោក អៀង សារី លើកជាទឡ្ហីករណ៍នៅក្នុងកថាខណ្ឌ ៦ នៃសំណើសុំរបស់ លោក អៀង សារី ថា បើខ្លួនគ្មានលទ្ធភាពពិនិត្យមើលឯកសារសម្ងាត់បំផុតទាំងនោះទេ ក្រុមមេធាវីការពារក្តីនឹង "មិនដឹងថាតើខ្លួនត្រូវចាំបាច់ ឬពុំចាំបាច់បដិសេធលើការទទួលយកឯកសារទាំងនោះ ថាតើឯកសារទាំងនោះរួមមាន ឬក៏ពុំមានសម្ភារៈដោះបន្ទុក ឬថាតើឯកសារទាំងនោះចាំបាច់ ឬពុំចាំបាច់សម្រាប់បង្ហាញអំពីបរិបទពាក់ព័ន្ធដែរឬទេ"[15]។ ក្រុមមេធាវីការពារក្តីសន្មតថា គ្រប់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង គឺមានលក្ខណៈជាភស្តុតាងទាំងអស់។ នេះគឺជាការសន្មតមិនត្រឹមត្រូវ។ យ៉ាងហោចណាស់ មានឯកសារចំនួន ១.១៨៦ នៅក្នុងសំណុំរឿង ដែលមិនទំនងជាសម្ភារៈភស្តុតាងនោះទេ។ ហេតុដូច្នេះ ឯកសារទាំងនេះនឹងមិនត្រូវបានបង្ហាញដល់ភាគីណាមួយនៅក្នុងអំឡុងពេលសវនាការឡើយ ហើយ ជាលទ្ធផល មិនមានភាពចាំបាច់ណាមួយសម្រាប់ឱ្យក្រុមមេធាវីការពារក្តីវាយតម្លៃលើខ្លឹមសាររបស់ឯកសារទាំងនេះ មុនពេលសវនាការលើអង្គសេចក្តីឡើយ។

១៨. នៅក្នុងចំណោមឯកសារចំនួន ៤.៤៣២ ដែលមានក្នុងបញ្ជីនៃឧបសម្ព័ន្ធភ្ជាប់ជាមួយនឹងសំណើសុំនេះ ហើយដែលត្រូវបានយោងធ្វើជាឯកសារ E118.1.1 នោះ យ៉ាងហោចណាស់ ឯកសារចំនួន ៧២៨ ខុសៗគ្នា[16] ជាប់ពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ។ ជាគោល ឯកសារទាំងនោះ រួមមានរបាយការណ៍វេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធនានា ដូចជា អនុស្សរណៈ លិខិត វិធាន សារណា ឬ សេចក្តីសម្រេចនានា ដែលទំនងជាត្រូវបានភ្ជាប់ជាបណ្តាញទៅនឹងរបាយការណ៍វេជ្ជសាស្ត្រ តាមរយៈលេខឯកសារដើម។ សហព្រះរាជអាជ្ញាមិនអាចកំណត់បានថាតើរបាយការណ៍វេជ្ជសាស្ត្រ និងឯកសារពាក់ព័ន្ធនានា ទាក់ទងទៅនឹងបុគ្គលណាមួយបានទេ លុះត្រាណានៅត្រង់ចំណុច ប្រភេទកំណត់ត្រា (Record Type) និងត្រង់ចំណុចភាគីដាក់ឯកសារ (Filing Party) មានបញ្ជាក់ពីព័ត៌មាននេះ។ ប៉ុន្តែ វាទំនងជាអង្គភាពវេជ្ជសាស្ត្រនៃ អ.វ.ត.ក គឺជាអ្នកដាក់ឯកសារភាគច្រើននៃឯកសារចំនួន

---

[15] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, កថាខណ្ឌ ៦។

[16] មានឯកសារចំនួន ១.២០២ ដែលក្នុងនោះ ៤៧៤ គឺជាឯកសារបកប្រែ។ ឯកសារទាំងនេះ អាចត្រូវបានពិចារណាថាមិនមែនជាសម្ភារៈភស្តុតាង លើកលែងតែរបាយការណ៍ផ្លូវចិត្ត/វិកលចារឹត ដែលអាចជាភស្តុតាង ពាក់ព័ន្ធទៅនឹងចេតនារបស់ជនជាប់ចោទ ហើយជាលទ្ធផល សម្រាប់សម្រេចអំពីការផ្តន្ទាទោសសមស្រប។ ប៉ុន្តែ ផ្អែកតាមបញ្ជីសារពើភ័ណ្ឌ គេមិនអាចកំណត់អត្តសញ្ញាណស្តីពីរបាយការណ៍ផ្លូវចិត្ត/វិកលចារឹតបានទេ នៅក្នុងឯកសារពាក់ព័ន្ធនឹងខុសភាពនោះ។

៧២៨ ទាំងនោះ ហើយឯកសារដែលនៅសល់ ត្រូវបានដាក់ដោយក្រុមមេធាវីការពារក្តី ក.ស.ច.ស អង្គជំនុំជម្រះ ឬអង្គភាពផ្សេងៗទៀត (ដោយអាចរួមទាំង មន្ទីពេទ្យកាល់ម៉ែត្រ ផងដែរ)។ ក្នុងចំណោមឯកសារវេជ្ជសាស្ត្រចំនួន ៧២៨ ទាំងនេះ យ៉ាងហោចណាស់ឯកសារចំនួន ៦២ ពាក់ព័ន្ធទៅនឹង ឬត្រូវបានដាក់ដោយ លោក អៀង សារី ហើយគួរអាចឱ្យក្រុមមេធាវីការពារក្តីរបស់ លោក អៀង សារី ពិនិត្យមើលបាន។ សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីដទៃទៀត មិនអាចពិនិត្យមើលឯកសារទាំងនេះបានទេ។ ស្រដៀងគ្នានេះដែរ មានឯកសារសម្ងាត់បំផុតមួយចំនួនច្រើន ដែលមានតែ អ្នកស្រី អៀង ធីរិទ្ធ ទេដែលអាចពិនិត្យមើលបាន[17]។

១៩. ក្រុមមេធាវីការពារក្តីរបស់ លោក អៀង សារី គួរតែបានកត់សម្គាល់ថា ឯកសារដែលពាក់ព័ន្ធទៅនឹងបញ្ហាសុខភាពនានា ត្រូវបានចាត់ប្រភេទបានយ៉ាងសមស្របថា "សម្ងាត់បំផុត" ដោយអនុលោមតាមគោលការណ៍សន្មតទុកជាមុន ដូចមានចែងនៅក្នុងមាត្រា ៦ (គ) នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ។ ដោយអនុលោមតាមគោលការណ៍រក្សាការសម្ងាត់វេជ្ជសាស្ត្រ និងគោលការណ៍គោរពជីវិតឯកជន វាមិនសមស្របទេ ប្រសិនបើឯកសារវេជ្ជសាស្ត្រនានា ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយនោះ។ ដូចសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីដែលមិនជាប់ពាក់ព័ន្ធដោយផ្ទាល់នោះ សហព្រះរាជអាជ្ញាក៏មិនអាចពិនិត្យមើលឯកសារពាក់ព័ន្ធនឹងបញ្ហាសុខភាពទាំងនេះបានដែរ លើកលែងតែឯកសារដែលសហព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតដោយអង្គជំនុំជម្រះសាលាដំបូងឱ្យពិនិត្យមើល ដើម្បីត្រៀមរៀបចំសម្រាប់សវនាការស្តីពីសម្បទាក្នុងការចូលរួមការជំនុំជម្រះក្តីតែប៉ុណ្ណោះ ដូចជា សវនាការដែលបានប្រព្រឹត្តិនៅចុង ខែ សីហា ឆ្នាំ ២០១១[18]។ សូម្បីតែនៅក្នុងក្របខណ្ឌដ៏តូចចង្អៀតនៃសវនាការក្នុង ខែ សីហា ឆ្នាំ ២០១១ នោះក៏ដោយ ក៏សហព្រះរាជអាជ្ញាមិនត្រូវបានអនុញ្ញាតឱ្យពិនិត្យឯកសារជាទូទៅនោះដែរ។ ផ្ទុយទៅវិញ មានតែសហព្រះរាជអាជ្ញា និងសហព្រះរាជអាជ្ញារងតែប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលឯកសារជាក់លាក់ ដែលចាំបាច់តែប៉ុណ្ណោះ។ អនុលោមតាមវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត សេចក្តីសម្រេចពាក់ព័ន្ធនឹងការអនុញ្ញាតឱ្យពិនិត្យមើលឯកសារ គឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង[19]។

---

[17] ឧទាហរណ៍ ឯកសារ **A275, B37/7, B37/8** ឬ **E52.3**។

[18] ឯកសារ **E62/3/10**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងជូនចំពោះមេធាវីរបស់ភាគី, ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១។

[19] ឯកសារ **E62/3/10**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងជូនចំពោះមេធាវីភាគី, ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១, ទំព័រ ១។

២០. តាមទស្សនៈជាក់ស្តែង ភាគីដែលមិនមែនជាភាគីដាក់ឯកសារ ឬដាក់សារណាតប មិនត្រូវមានការរំពឹងទុកថាអាចពិនិត្យមើលឯកសារវេជ្ជសាស្ត្ររបស់ជនជាប់ចោទឡើយ[20]។ ហេតុដូច្នេះ សំណើសុំរបស់ លោក អៀង សារី គួរត្រូវបានច្រានចោល ដោយហេតុថា សំណើសុំនេះពាក់ព័ន្ធទៅនឹងឯកសារវេជ្ជសាស្ត្ររបស់ជនជាប់ចោទដទៃទៀត។ បន្ថែមលើនេះ ដូចបានលើកឡើងដោយក្រុមមេធាវីការពារក្តីរបស់ អ្នកស្រី អៀង ធីរិទ្ធ នៅក្នុងញត្តិរបស់ខ្លួន ការមិនលាតត្រដាងនូវព័ត៌មានវេជ្ជសាស្ត្របែបនេះ នឹងមិនមានការប៉ះពាល់ណាមួយដល់សិទ្ធិរបស់ លោក អៀង សារី ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ឡើយ[21]។

២១. ក្រៅពីឯកសារវេជ្ជសាស្ត្រសម្ងាត់បំផុតទាំងនេះ ការវិភាគត្រួសៗទៅលើចំណុច "ប្រភេទកំណត់ត្រា" និងចំណុច "ភាគីដាក់ឯកសារ" នៅក្នុងបញ្ជីសារពើភ័ណ្ឌនៃផ្នែកសម្ងាត់បំផុតនោះ បង្ហាញឱ្យឃើញថា ឯកសារមួយចំនួន គឺជា ឬអាចជាឯកសាររដ្ឋបាល ឬឯកសារស្តីពីនីតិវិធី ដែលមិនមែនជាភស្តុតាង។ សហព្រះរាជអាជ្ញាជឿជាក់ថា របាយការណ៍ចំនួន ៤៥៨ ដែលដាក់ដោយផ្នែកគ្រប់គ្រងតុលាការ (E29—E29/453) រួមមានរបាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដែលវាយតម្លៃអំពីហានិភ័យនៃសន្តិសុខ និងភាពចាំបាច់ ឬវិធានការការពារ ដែលបានស្នើឡើងដោយអ្នកប្តឹង ឬដើមបណ្តឹងរដ្ឋប្បវេណី។ ប្រភេទឯកសារទាំងនេះ ដែលអាចបញ្ជាក់បន្ថែមដោយអង្គជំនុំជម្រះសាលាដំបូងចំពោះលក្ខណៈពិតប្រាកដនៃរបាយការណ៍របស់អង្គភាពគ្រប់គ្រងតុលាការទាំងនេះ ទំនងជាឯកសារ ដែលមិនមានលក្ខណៈជាភស្តុតាងនោះទេ ហើយត្រូវបានចាត់ប្រភេទយ៉ាងសមស្របថាជាឯកសារសម្ងាត់បំផុត ដោយអនុលោមតាមគោលការណ៍សន្មតទុកជាមុន នៅក្នុងមាត្រា ៦ ៩ក) នៃសេចក្តីណែនាំអនុវត្តស្តីពីការចាត់ប្រភេទឯកសារ។

២២. ប្រសិនបើការសង្កេតនានារបស់សហព្រះរាជអាជ្ញាមានភាពត្រឹមត្រូវនោះ ឯកសារសម្ងាត់បំផុតនៃបញ្ជីសារពើភ័ណ្ឌក្នុងសំណុំរឿង មានឯកសារដែលមិនមែនជាភស្តុតាង យ៉ាងហោចណាស់ ចំនួន ១.១៨៦។ ឯកសារទាំងនេះ មានចំនួនច្រើនជាងមួយភាគបួននៃឯកសារសម្ងាត់បំផុតចំនួន ៤.៤៣២ ដែលមាននៅក្នុងបញ្ជីនៃឧបសម្ព័ន្ធ E118.1.1។ ប្រសិនបើក្រុមមេធាវីការពារក្តីរបស់ លោក អៀង

---

[20] ឯកសារ **E62/3/10**, អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូងជូនចំពោះភាគី, ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១, ទំព័រ ១។

[21] ឯកសារ **E118/1**, ញត្តិរបស់អ្នកស្រី អៀង ធីរិទ្ធ, កថាខណ្ឌ ៧។

សារី បានធ្វើការវិភាគជាមូលដ្ឋាន ដូចបានរៀបរាប់ពីខាងលើ ក្រុមមេធាវីការពារក្តីនឹងមិនស្នើសុំការអនុញ្ញាតដើម្បីពិនិត្យមើលឯកសារទាំងនេះនោះឡើយ។

**គ. ស្ថានភាពនៃឯកសារសម្ងាត់បំផុតដែលជា/អាចជាឯកសារពាក់ព័ន្ធនឹងភស្តុតាង**

២៣. ឯកសារ "សម្ងាត់បំផុត" ដែលនៅសេសសល់ចំនួន ៣.២៤៦ អាចជាឯកសារពាក់ព័ន្ធនឹងភស្តុតាងដោយផ្ទាល់ ឬដោយប្រយោល។

<u>សំណើសុំវិធានការការពាររបស់ជនរងគ្រោះ</u>

២៤. ក្នុងចំណោមឯកសារទាំងអស់នោះ ឯកសារពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬពាក់ព័ន្ធនឹងពាក្យបណ្តឹង មានចំនួនប្រហែល ៣.១៣២។ តារាងបញ្ជីឯកសារសម្ងាត់បំផុតបង្ហាញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ១.៣៥៥ និងឯកសារពាក់ព័ន្ធ (ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ៣៧០ នាក់) ត្រូវបានដាក់ដោយអង្គភាពជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណីខ្លួនឯងផ្ទាល់ ឬ ក.ស.ច.ស ហើយក្នុងនោះមានទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ, ឯកសារភ្ជាប់មួយចំនួនដូចជា សេចក្តីបញ្ជាក់, អនុស្សរណៈ, និង របាយការណ៍ ឬដីកាសម្រេចរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹងវិធានការការពារ។ ឯកសារប្រភេទនេះភាគច្រើន ឬទាំងអស់ មានលេខយោង D22 នៅខាងដើម។ តាមតារាងបញ្ជីឯកសារសម្ងាត់បំផុតដដែលនេះ បង្ហាញថា សហព្រះរាជអាជ្ញាបានដាក់ពាក្យបណ្តឹង ឬឯកសារពាក់ព័ន្ធទៅ ក.ស.ច.ស ចំនួនប្រហែល ១.៧៧៧ ដែលត្រូវបានដាក់ចំណាត់ថ្នាក់ជា "សម្ងាត់បំផុត" កាលពីពេលនោះ ដោយអនុលោមតាមវិធាន ៤៩(៤)។ ឯកសារទាំងអស់នោះពាក់ព័ន្ធនឹងម្ចាស់បណ្តឹងចំនួន ៦៦៥ នាក់។ ឯកសារប្រភេទនេះភាគច្រើន ឬទាំងអស់មានលេខយោង D230 នៅខាងដើម ហើយក្នុងនោះមានទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ, សេចក្តីសង្ខេបជាភាសាអង់គ្លេសរបស់អង្គភាពជនរងគ្រោះ និង/ឬ ឯកសារភ្ជាប់ផ្សេងៗដូចជាប្រវត្តិរូបជាដើម។

២៥. ក្នុងចំណោមឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងឯកសាររបស់ម្ចាស់បណ្តឹងចំនួនទាំង ៣.១៣២ គ្មានឯកសារណាមួយដែលសហព្រះរាជអាជ្ញាអាចពិនិត្យមើលនៅក្នុងប្រព័ន្ធ Zylab បានឡើយ។ ទោះ

យ៉ាងនេះក្តី សហព្រះរាជអាជ្ញាអាចពិនិត្យមើលពាក្យបណ្តឹងចំនួន ១.៧៧៧ ឬឯកសារពាក់ព័ន្ធតាមរយៈប្រព័ន្ធទិន្នន័យរបស់ខ្លួន (ប្រព័ន្ធទិន្នន័យ CaseMap របស់ ក.ស.ព) ដោយហេតុថា ពួកគាត់បានដាក់ឯកសារទាំងអស់នោះទៅក្នុងសំណុំរឿង។ តាមរយៈការវិភាគលើការជ្រើសរើសដោយឥតព្រាងទុកចំពោះទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ដែលសហព្រះរាជអាជ្ញាបានដាក់ក្នុងសំណុំរឿងក្នុងប្រភេទជាពាក្យបណ្តឹង បង្ហាញថា ម្ចាស់បណ្តឹងដែលឯកសាររបស់ពួកគាត់ត្រូវបានដាក់ចូលទៅក្នុងតារាងបញ្ជីឯកសារសម្ងាត់បំផុត សុទ្ធតែបានស្នើសុំវិធានការការពារចាប់តាំងពីដំណាក់កាលដើមដំបូង។ ស្រដៀងគ្នានេះ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារពាក់ព័ន្ធដែលមានរៀបរាប់ក្នុងឯកសារ E118.1.1 ទំនងជាពាក់ព័ន្ធនឹងជនរងគ្រោះដែលបានស្នើសុំវិធានការការពារនៅពេលពួកគាត់ដាក់ពាក្យសុំ។ យើងត្រូវកត់សម្គាល់ថា មានពាក្យបណ្តឹងចំនួន ៤១៤ តែប៉ុណ្ណោះ (បើប្រៀបធៀបទៅនឹងម្ចាស់បណ្តឹងចំនួន ៤.២២៨ នាក់) ដែលមាននៅក្នុងឧបសម្ព័ន្ធ ១៣ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ដែលបានដាក់កាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ កន្លងទៅ។ ហើយក្នុងចំណោមពាក្យបណ្តឹងទាំង ៤១៤ នេះទៀតសោត មានតែមួយផ្នែកប៉ុណ្ណោះដែលបានស្នើសុំវិធានការការពារ។

២៦. ទាំង អៀង សារី និង អៀង ធីរិទ្ធ សុទ្ធតែពុំអាចពុំអើពើទៅនឹងបញ្ហាជាក់ស្តែងដែលថា សំណើសុំវិធានការការពារ និងឯកសារពាក់ព័ន្ធ (ក្នុងនោះរួមមាន ការវាយតម្លៃអំពីហានិភ័យរបស់អង្គភាពគាំពារអ្នកជំនាញ និងសាក្សី ដូចដែលបានពិភាក្សាខាងលើត្រង់កថាខណ្ឌ១៩) ព្រមទាំងឯកសារ និងព័ត៌មានពាក់ព័ន្ធនឹងវិធានការការពារ ត្រូវបានសន្មតថាជា ឯកសារសម្ងាត់បំផុត ដោយអនុលោមតាមមាត្រា ៦(ក) និង (ខ) នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ។ ហេតុដូច្នេះ ជាការសមស្រប ដែលឯកសារទាំងអស់នោះត្រូវបានដាក់ចំណាត់ថ្នាក់ជាឯកសារ "សម្ងាត់បំផុត" ក្នុងអំឡុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលមុនសវនាការ។ ជនរងគ្រោះ និងសាក្សី មានសិទ្ធិស្នើសុំវិធានការការពារ[22] ហើយតុលាការមានកាតព្វកិច្ចធានាថា ជនរងគ្រោះទាំងអស់ដែលចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនឹងទទួលបានការការពារ ដោយពុំគិតអំពីឋានៈជនរងគ្រោះនៅចំពោះមុខ

[22] សេចក្តីណែនាំអនុវត្តន៍ស្តីពីវិធានការការពារ, អ.វ.ត.ក/ ០៣/២០០៧/ វិសោធនកម្មលើកទី ១, មាត្រា ២។

តុលាការឡើយ[23]។ វិធានការការពារទាំងនេះជាវិធានការសមស្របដើម្បីធានាសុវត្ថិភាព និងការសម្ងាត់របស់ជនរងគ្រោះ នៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធី ទោះបីវិធានការទាំងនេះត្រូវថ្លឹងថ្លែងជាមួយសិទ្ធិជនជាប់ចោទក្នុងការពិនិត្យសំណុំរឿងព្រហ្មទណ្ឌក្តី។ នៅក្នុងករណីចាំបាច់ វិធានការការពារគឺជាសិទ្ធិជាសារវ័ន្តមួយរបស់ជនរងគ្រោះនៅក្នុងការជំនុំជម្រះឧក្រិដ្ឋកម្ម ឬឧក្រិដ្ឋកម្មអន្តរជាតិ។

២៧. វិធាន ២៩ នៃវិធានផ្ទៃក្នុង រក្សាតុល្យភាពរវាងការការពារជនរងគ្រោះ និងសិទ្ធិរបស់ជនជាប់ចោទ។ ជាក់ស្តែង វិធាននេះបានអនុញ្ញាតឲ្យមានការប្តឹងឧទ្ធរណ៍ជំទាស់នឹងវិធានការការពារដែលអង្គជំនុំជម្រះបានសម្រេច។ វិធានខាងលើក៏បានចែងថា ជនជាប់ចោទពុំអាចរងការផ្តន្ទាទោសណាមួយឡើយ ដោយគ្រាន់តែសំអាងទៅលើចម្លើយរបស់សាក្សី ដែលស្ថិតក្រោមវិធានការការពារ។

២៨. អនុលោមតាមមាត្រា ៧(៣) ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានចាត់ទុកជាឯកសារសម្ងាត់បំផុត*រហូតដល់ពេលមានសេចក្តីសម្រេចលើសំណើសុំវិធានការការពារ*[24]។ ដើម្បីរក្សាភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី និងអនុញ្ញាតឲ្យមេធាវីការពារក្តី និងភាគីផ្សេងៗ អាចពិនិត្យភស្តុតាងដែលមាននៅក្នុងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬម្ចាស់បណ្តឹងក្នុងអំឡុងដំណាក់កាលជំនុំជម្រះ និងពិសេសឯកសារដែលភាគីបានលើកឡើងក្នុងសវនាការ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ចេញដីកាបង្គាប់ឲ្យបានឆាប់រហ័សស្តីពីវិធានការការពារដែលដើមបណ្តឹងរដ្ឋប្បវេណី និងម្ចាស់បណ្តឹង បានស្នើសុំ ដោយផ្អែកលើរបាយការណ៍វាយតម្លៃហានិភ័យរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងឯកសារដែលអង្គភាពជនរងគ្រោះបានប្រគល់ជូន។ អង្គជំនុំជម្រះសាលាដំបូងនឹងបែងចែករវាងវិធានការការពារ ដែលបានស្នើសុំពាក់ព័ន្ធទៅនឹងសាធារណៈជន (សាធារណៈទល់នឹងសម្ងាត់) និងវិធានការការពារពាក់ព័ន្ធនឹងភាគី (សម្ងាត់ ទល់នឹង សម្ងាត់បំផុត)។ សារណាតបនេះពិចារណាទៅលើវិធានការការពារពាក់ព័ន្ធនឹងភាគីតែប៉ុណ្ណោះ ។

---

[23] វិធានផ្ទៃក្នុង វិធាន២៩(១)។

[24] គូសបញ្ជាក់បន្ថែម។

២៩. ប្រសិនបើសំណើសុំវិធានការការពារបាននេះត្រូវបានបដិសេធ វាអាស្រ័យទៅលើការប្ដឹងឧទ្ធរណ៍សហព្រះរាជអាជ្ញារំពឹងថាអង្គជំនុំជម្រះសាលាដំបូង នឹងដកឯកសារពាក់ព័ន្ធចេញពីផ្នែកសម្ងាត់បំផុតនៃសំណុំរឿង និងដាក់ចំណាត់ថ្នាក់ជាឯកសារសម្ងាត់វិញ ដូចធ្លាប់បានធ្វើនាពេលកន្លងនៅក្នុងសេចក្ដីសម្រេចរបស់ខ្លួនស្ដីពីវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១[25]។ ហេតុដូច្នេះ សំណើរបស់ អៀង សារី និង អៀង ធីរិទ្ធ មិនទាន់ដល់ពេលដាក់ឡើយ ទាក់ទិននឹងសំណុំឯកសារសម្ងាត់បំផុតមួយនេះ។ ប៉ុន្តែប្រសិនបើវិធានការការពារបានទទួលការឯកភាព[26] អង្គជំនុំជម្រះសាលាដំបូងនឹងរក្សាទុកចំណាត់ថ្នាក់សម្ងាត់បំផុត និងបង្កើតឯកសារទាំងនេះក្នុងប្រភេទជាឯកសារសម្ងាត់ ដែលភាគីអាចពិនិត្យមើល ដោយអង្គជំនុំជម្រះនឹងលុបចេញនូវផ្នែកដែលអាចធ្វើឱ្យភាគីស្គាល់អត្តសញ្ញាណបុគ្គលពាក់ព័ន្ធ ដោយអនុលោមតាមបញ្ញត្តិនៃវិធាន ២៩(៤),មាត្រា ៧(១) និងមាត្រា ៩ (២) នៃសេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ចំណាត់ថ្នាក់ ឯកសារ និងមាត្រា ៣(១៤) នៃសេចក្ដីណែនាំអនុវត្តន៍ស្ដីពីការដាក់ឯកសារនៅ អ.វ.ត.ក។ តាមរយៈការអនុវត្តបែបនេះ អង្គជំនុំជម្រះសាលាដំបូងនឹងគោរពតម្រូវការរបស់ជនរងគ្រោះ និងសាក្សី សិទ្ធិរបស់ជនជាប់ចោទ និងភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធីដោយអនុលោមតាមមាត្រា ១ (៣) នៃសេចក្ដីណែនាំអនុវត្តន៍ស្ដីពីវិធានការការពារ។

---

[25] ឯកសារ **D288/6.71**, សំណុំរឿងលេខ ០០១, សេចក្ដីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី, ចុះ ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៩, ទំព័រ ៧ (ផ្នែកគ្រប់គ្រង)។

[26] ជាឧទាហរណ៍, វិធានការការពារត្រូវបានផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណី E2/62 និង KW-24 នៅក្នុងឯកសារ **D288/6.135**, សំណុំរឿងលេខ ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្ដីសម្រេចលើសំណើសុំវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០០៩។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងធ្លាប់បានគូសបញ្ជាក់នៅក្នុង សេចក្ដីមួយទៀតក្នុងសំណុំរឿង ០០១, "យុត្តិសាស្ត្រដែលត្រូវបានបង្កើតឡើងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏បានបង្ហាញផងដែរថា វិធានការការពារត្រូវបានផ្ដល់ឱ្យតាមករណីនីមួយៗ នៅពេលដែលសំណើនោះមានព័ត៌មានគ្រប់គ្រាន់ស្ដីពីអត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំ និងការបញ្ជាក់លម្អិតអំពីហានិភ័យ ឬព្យសនកម្មដែលអ្នកដាក់ពាក្យសុំ ឬគ្រួសាររបស់ពួកគេនឹងត្រូវប្រឈម។ បន្ថែមពីនេះទៀត ពាក្យសុំនោះចាំបាច់តម្រូវឱ្យមានបញ្ជាក់ពីការភ័យខ្លាចពិតប្រាកដរបស់ អ្នកដាក់ពាក្យសុំ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងមូលហេតុសមស្របចំពោះការភ័យខ្លាចនោះ" ឯកសារ **D288/6.71**, សំណុំរឿង ០០១, អង្គជំនុំជម្រះសាលាដំបូង, សេចក្ដីសម្រេចអំពីវិធានការការពារសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី, ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០០៩, កថាខណ្ឌ ៧ និងជើងទំព័រ ១៧។

៣០. ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវពិចារណាលើសំណើសុំវិធានការការពារ ដែលមានចំនួនច្រើន សហព្រះរាជអាជ្ញាសូមអះអាងថា ប្រសិនបើភាគីកំណត់អត្តសញ្ញាណ និងកំណត់អាទិភាពដល់ពាក្យបណ្ដឹងសម្ងាត់បំផុត ដែលត្រូវបានដាក់បញ្ចូលក្នុងបញ្ជីឯកសារសម្រាប់សវនាការ ឬពាក់ព័ន្ធឯកសារព័ន្ធនឹងសាក្សីសម្រាប់ការជំនុំជម្រះដែលភាគីបានស្នើសុំកោះហៅ នោះនឹងអាចជួយសម្រាលបញ្ហាបានមួយកម្រិត។ ហើយស្រដៀងគ្នានេះ ភាគីគួរកំណត់អាទិភាពចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលពាក់ព័ន្ធនឹងដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះ ដែលភាគីណាមួយបានស្នើសុំកោះហៅឲ្យផ្ដល់សក្ខីកម្ម ឬឆ្លើយបំភ្លឺនៅសវនាការ។

៣១. សហព្រះរាជអាជ្ញាសូមអះអាងជាថ្មីម្ដងទៀតថា អង្គជំនុំជម្រះសាលាដំបូងគួរបដិសេធសំណើរបស់ អៀង សារី[27] ដែលបានស្នើសុំពិនិត្យមើលរាល់ឯកសារសម្ងាត់បំផុត *ទាំងអស់* ពាក់ព័ន្ធនឹងឯកសារដែលពាក់ព័ន្ធនឹងវិធានការការពារដែលនាំឲ្យមានការដាក់ចំណាត់ថ្នាក់ថាជា "ឯកសារសម្ងាត់បំផុត"។ ផ្ទុយទៅវិញ ប្រសិនបើសំណើខាងលើត្រូវបានអង្គជំនុំជម្រះសាលាដំបូងឯកភាព សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការដាក់កំហិត ដើម្បីការពារអត្តសញ្ញាណជនរងគ្រោះ និងសមាជិកគ្រួសាររបស់ពួកគាត់។

## ឯកសារផ្សេងៗ

៣២. ក្រៅពីឯកសារចំនួន ៣.១៣២ ពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឬពាក្យបណ្ដឹង បញ្ជីឯកសារនេះនៅមានឯកសារចំនួន ១១៤ ទៀត ដែលអាចជាឯកសារពាក់ព័ន្ធនឹងភស្តុតាង។ ផ្អែកតាមព័ត៌មាននៅក្នុងបញ្ជីឯកសារនេះ យើងពុំអាចបញ្ជាក់ប្រភេទឯកសារទាំងអស់នោះឲ្យបានពេញលេញឡើយ។ ទោះយ៉ាងនេះក្ដី វាហាក់ដូចជាថា ក្នុងចំណោមឯកសារទាំងនោះ មានឯកសារចំនួន ៥០ គឺជាដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ ក.ស.ច.ស ដីកាសម្រេច ឬជារបាយការណ៍។ ផ្អែកតាម

---

[27] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, ទំព័រ ១, កថាខណ្ឌផ្ដើម, មានដូចគ្នានៅក្នុងកថាខណ្ឌ ៤, ៦, ៨ និងនៅក្នុងសេចក្ដីសន្និដ្ឋាននៃសំណើនេះ។

ឯកសារដើមរបស់ពួកគេ[28] ឯកសាររបស់ ក.ស.ច.ស. ទាំងអស់នេះ មានបំណងប្រមូលភស្តុតាងពីសាស្ត្រាចារ្យ/អ្នកស្រាវជ្រាវនៅឯបរទេស ឬប្រមូលភស្តុតាងពីប្រទេសក្រៅតាមរយៈតំណាងការទូតរបស់ខ្លួន។ សហព្រះរាជអាជ្ញាពុំដឹងអំពីមូលហេតុនៃការដាក់ចំណាត់ថ្នាក់ឯកសាររបស់ ក.ស.ច.ស ទាំងអស់នេះជា "ឯកសារសម្ងាត់" ឡើយ។

៣៣. សហព្រះរាជអាជ្ញាសូមអះអាងថា អង្គជំនុំជម្រះសាលាដំបូង គួរពិចារណាអំពីការដាក់ចំណាត់ថ្នាក់ឡើងវិញទៅលើឯកសារ ក.ស.ច.ស ដែលមានលេខសម្គាល់ D359/1/Corr-1, D368/Corr-1, D369/Corr-1, D372/Corr-1, D373/Corr-1 ទៅក្នុងផ្នែកសម្ងាត់នៃសំណុំរឿង ដោយហេតុថាភាគីអាចពិនិត្យមើលឯកសារទាំងនេះក្នុងសំណៅដើមនៅក្នុង Zylab។ ស្រដៀងគ្នានេះ ភាគីក៏អាចពិនិត្យមើលឯកសារ ក.ស.ច.ស ដែលមានលេខយោង D389.1 បានផងដែរក្នុង Zylab ក្នុងផ្នែកសម្ងាត់នៃសំណុំរឿង។ ឯកសារ ក.ស.ច.ស ដែលមានលេខសម្គាល់ D389.2, D405, D407, D413, D421, D422 និង D425 ពុំមានបញ្ជាក់ប្រភេទ ឬខ្លឹមសារសោះឡើយ។

៣៤. ក្នុងចំណោមឯកសារទាំង ១១៤ ដែលពុំពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឬពាក្យបណ្តឹង ក៏មានឯកសារបណ្តឹងឧទ្ធរណ៍ដែល នួន ជា បានដាក់ពាក់ព័ន្ធនឹងសំណើសុំបំពេញកិច្ចស៊ើបសួរដែរ[29]។ ជាចុងក្រោយ ឯកសារមួយចំនួនតូចដែលភាគី "ផ្សេងៗ" បានដាក់ ពុំអាចត្រូវបានកំណត់អត្តសញ្ញាណ ឬដាក់ចំណាត់ថ្នាក់សោះឡើយ ដែលធ្វើឱ្យសហព្រះរាជអាជ្ញាពុំមានលទ្ធភាពអះអាងថាគួរដាក់ចំណាត់ថ្នាក់ឯកសារទាំងនេះដូចម្តេចឡើយ។

៣៥. ដោយសារកង្វះព័ត៌មានពាក់ព័ន្ធនឹងឯកសារបន្ថែមចំនួន ១១៤ នេះ សហព្រះរាជអាជ្ញាសូមស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការវាយតម្លៃអំពីខ្លឹមសារ និងដាក់ចំណាត់ថ្នាក់ឯកសារទាំងអស់នោះ ដើម្បីធានាថាភាគីអាចពិនិត្យមើលឯកសារទាំងអស់នោះបាន ដោយអនុលោមតាមសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ។

---

[28] ឯកសារ **D269**, **D291**, **D292**, **D293**, **D294** ឬ **D308/2**។

[29] ឯកសារចំនួន ៥ ដែលមានលេខសម្គាល់ D273/3/1 នៅខាងដើម។

## ឃ. ចំណងជើងនៃឯកសារសម្ងាត់បំផុតគួរមាននៅក្នុងបញ្ជីឯកសារ

៣៦. សហព្រះរាជអាជ្ញាសូមអះអាងថា អនុលោមតាមមាត្រា ១០(ខ) និងមាត្រា១០(គ) នៃសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ អង្គជំនុំជម្រះសាលាដំបូងគួរកែប្រែបញ្ជីឯកសារត្រង់ផ្នែកសម្ងាត់បំផុត ដើម្បីសរសេរចំណងជើងពេញលេញនៃឯកសារទាំងអស់ ឬចំណងជើងក្នុងសំណៅកោសលប់តាមការចាំបាច់ កុំឱ្យដូចបច្ចុប្បន្នដែលមានតែប្រភេទឯកសារទូទៅ។ នេះជាវិធានការចាំបាច់មួយ ពិសេសសម្រាប់ឯកសារដែលយើងពុំអាចកំណត់ប្រភេទរបស់វាបានត្រឹមត្រូវ ដោយផ្អែកតាមទិន្នន័យបញ្ជីឯកសារដែលមានស្រាប់ ឬតាមរយៈការយោងទៅលើឯកសារដើមក្នុង Zylab។ ទោះបីសហព្រះរាជអាជ្ញាឯកភាពទៅនឹងការលើកឡើងរបស់ អៀង សារី ដែលថា ការបង្ហាញត្រឹមតែព័ត៌មានទូទៅ ហើយមិនបង្អើបខ្លឹមសារសម្ងាត់បំផុតរបស់ឯកសារទាំងអស់នោះ[30] ពុំទាន់គ្រប់គ្រាន់ដើម្បីឱ្យភាគីមានលទ្ធភាពយល់អំពីប្រភេទនៃឯកសារទាំងនេះក្តី ក៏សហព្រះរាជអាជ្ញាពុំឯកភាពទៅនឹងការសន្និដ្ឋានរបស់មេធាវីការពារក្តីឡើយ។ មេធាវីការពារក្តីបានអះអាងថា ការបង្ហាញឯកសារនេះ "មិនគ្រប់គ្រាន់ក្នុងការប៉ះប៉ូវចំពោះការប៉ះពាល់ដល់សិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់លោក អៀង សារី"[31]។ ទោះយ៉ាងនេះក្តី ដូចដែលបានពន្យល់ខាងលើ ពុំមានអ្វីបញ្ជាក់ថា សិទ្ធិរបស់ អៀង សារី ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ បានទទួលរងការរំលោភបំពានដោយសារពុំមានការបង្ហាញសម្ភារៈដែលមិនមានតម្លៃជាភស្តុតាង ឬតាមរយៈការដាក់ចំណាត់ថ្នាក់បឋមលើឯកសារភស្តុតាង ដែលពាក់ព័ន្ធនឹងវិធានការការពារថាជា "ឯកសារសម្ងាត់" ឡើយ។

## ង. ពុំមានការរំលោភលើគោលការណ៍សមភាពរវាងគូភាគីក្នុងការតទល់ក្តីឡើយ

---

[30] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, នៅក្នុងកថាខណ្ឌផ្តើម និងកថាខណ្ឌ ៩-១១, មេធាវីការពារក្តីបានលើកឡើងថា*ចំណងជើង*ទូទៅត្រូវបានបង្ហាញ។ ចំណុចនេះពុំពិតទេ ដោយហេតុថាបញ្ជីឯកសារពុំមានដាក់ចំណងជើងឡើយ លើកលែងតែប្រភេទឯកសារ, ភាគីដាក់ឯកសារ, លេខឯកសារ, លេខERN និងភាសាឯកសារ។ នៅក្រោមចំណងជើងថា 'Title EN' និង 'Title KH' យើងនឹងប្រទះឃើញពាក្យថា "សម្ងាត់បំផុត" ដែលជាចំណាត់ថ្នាក់ឯកសារ។

[31] ឯកសារ **E118**, សំណើរបស់លោក អៀង សារី, កថាខណ្ឌផ្តើម។ សូមមើលផងដែរ កថាខណ្ឌ ៩-១១។

៣៧. មេធាវីការពារក្តី អៀង សារី អះអាងថា ការដែលពួកគេគ្មានលទ្ធភាពពិនិត្យឯកសារ "សម្ងាត់បំផុត" គឺជាការរំលោភទៅលើគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីជាមួយការិយាល័យសហព្រះរាជអាជ្ញា ("ក.ស.ព")។ មេធាវីការពារក្តីបានលើកឧទាហរណ៍ចំនួន ៣ អំពីឯកសារសម្ងាត់បំផុត[32] ដែល ក.ស.ព បានលើកយកមកសំអាងដាច់ដោយឡែកពីគ្នានៅក្នុងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[33], បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការស្របតាមវិធាន ៨០ (៣)[34] និងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបានស្នើសុំឯកសារពាក់ព័ន្ធនឹងការជំនុំជម្រះលើអង្គសេចក្តីដំណាក់កាលដំបូង[35]។

៣៨. ដូចបានរៀបរាប់ខាងលើ សហព្រះរាជអាជ្ញាពុំអាចពិនិត្យឯកសារទាំងប៉ុន្មានដែលសហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះបានដាក់ចំណាត់ថ្នាក់ជាឯកសារ "សម្ងាត់បំផុត" នៅក្នុង Zylab បានឡើយ។ ឯកសារទាំង ៣ ដែលមេធាវីការពារក្តីរបស់ អៀង សារី បានលើកឡើងនោះ គឺសុទ្ធតែជាទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះទាំងអស់ ដែលម្ចាស់បណ្តឹងបានដាក់ និងបានស្នើសុំវិធានការការពារ។ ដូច្នេះជាគោលការណ៍ ឯកសារទាំងអស់នេះស្ថិតក្នុងផ្នែកសម្ងាត់បំផុតនៃសំណុំរឿង។ ក.ស.ព បានទទួលឯកសារទាំងអស់នេះពីអង្គភាពជនរងគ្រោះ បន្ទាប់មកខ្លួនបានពិនិត្យមើលឡើងវិញ និងបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត ដោយអនុលោមតាមវិធាន ៤៩(៤) នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញាអាចពិនិត្យមើលខ្លឹមសារនៃឯកសារទាំងអស់នេះ តាមរយៈមូលដ្ឋានទិន្នន័យរបស់ខ្លួន (ប្រព័ន្ធទិន្នន័យ CaseMap ក.ស.ព) មិនមែនតាមរយៈ Zylab ទេ។ ចំណាត់ការលើឯកសារទាំង

---

[32] ឯកសារ **D230/1.1.874a**, **D230/1.1.360a** និង **D230/2/2.1.241a**។ ឯកសារស៊េរី D230 ពាក់ព័ន្ធនឹងពាក្យសុំរបស់ជនរងគ្រោះដែលម្ចាស់បណ្តឹងបានដាក់។

[33] ឯកសារ **E9/4**, បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញារួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និងទី៥, ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១។

[34] ឯកសារ **E9/31**, បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០ (៣), ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១។

[35] ឯកសារ **E109/4**, ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទងទៅនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។

អស់នេះ និងឯកសារ “សម្ងាត់បំផុត” ដែលមេធាវីការពារក្តី អៀង សារី បានដាក់ គ្មានអ្វីខុសគ្នាជាដុំកំភួនឡើយ។ ជាងនេះទៅទៀត ជាការបំពានទៅលើគោលបំណងនៃគោលការណ៍របស់វិធានការការពារ ប្រសិនបើមេធាវីការពារក្តីអាចពិនិត្យឯកសារទាំងអស់នេះ នៅពេលពុំទាន់មានសេចក្តីសម្រេចលើសំណើសុំវិធានការទាំងអស់នេះទេ។

៣៩. ចំពោះសិទ្ធិរបស់ជនជាប់ចោទក្នុងការពិនិត្យមើលសំណុំរឿងព្រហ្មទណ្ឌរបស់ខ្លួន សហព្រះរាជអាជ្ញានៅតែប្រកាន់ជំហររបស់ខ្លួន ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ២៩ ពាក់ព័ន្ធនឹងសំណើសុំវិធានការការពារ ដែលម្ចាស់បណ្តឹង និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ និងការដាក់កំហិតលើការចែកចាយសំណើរបស់ពួកគេក្នុងទម្រង់កោសលប់ ក្នុងករណីចាំបាច់។

## IV. សំណើ

៤០. តាមសំអាងហេតុខាងលើ សហព្រះរាជអាជ្ញាសូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(ក) បដិសេធសំណើរបស់ អៀង សារី ត្រង់ចំណុចដែល អៀង សារី ស្នើសុំពិនិត្យដោយស្វ័យប្រវត្តទៅលើរាល់ឯកសារសម្ងាត់បំផុតទាំងអស់នៅក្នុងសំណុំរឿង (ឯកសារ ៤.៤៣២)។

(ខ) បដិសេធសំណើសុំបង្ហាញជាសាធារណៈនូវឯកសារមិនមែនភស្តុតាងទាំងអស់ដែលបានស្នើសុំ (ឯកសារចំនួនប្រមាណ ១.១៨៦)

(គ) បដិសេធសំណើរបស់ អៀង សារី និង ញត្តិរបស់ អៀង ធីរិទ្ធ ដែលបានស្នើសុំពិនិត្យឯកសារពាក់ព័ន្ធនឹងវិធានការការពារ (ឯកសារចំនួនប្រមាណ ៣.១៣២)

(ឃ) សម្រេចឱ្យបានរហ័សទៅលើសំណើសុំវិធានការការពារ ពាក់ព័ន្ធនឹងឯកសារទាំងអស់នេះ ដោយអនុលោមតាមកថាខណ្ឌ ៣០ ខាងលើ និង (១) ក្នុងករណីដែលសំណើនេះត្រូវបានបដិសេធ សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះដាក់ចំណាត់ថ្នាក់ឡើងវិញនូវឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬម្ចាស់បណ្តឹង ថាជាឯកសារសម្ងាត់ ឬ (២) ក្នុងករណីសំណើទាំងនេះបានទទួលការឯកភាព សហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះរក្សាទុកឯកសារទាំងនោះជាប្រភេទឯកសារសម្ងាត់បំផុត ប៉ុន្តែនៅមុនពេលសវនាការលើអង្គសេចក្តី បង្ហាញដល់ភាគីនូវសំណៅសម្ងាត់នៃភស្តុតាងក្នុងទម្រង់កោសលប់។

(ង) វាយតម្លៃទៅលើឯកសារចំនួនទាំង ១១៤ ដែលពុំមែនជាឯកសារពុំមែនភស្តុតាង ឬឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី/ម្ចាស់បណ្តឹង ដែលបានលើកយកមកពិចារណាខាងលើ ដើម្បី

ពិនិត្យចំណាត់ថ្នាក់ឯកសារទាំងនោះឡើងវិញ និងធានាថា ភាគីអាចពិនិត្យមើលឯកសារទាំងអស់នោះបាន ដោយអនុលោមតាមសេចក្តីណែនាំអនុវត្តន៍ស្តីពីការដាក់ចំណាត់ថ្នាក់ឯកសារ និង

(ច) កែប្រែបញ្ជីឯកសារសម្ងាត់បំផុតនៃសំណុំរឿង ដើម្បីដាក់បញ្ចូលចំណងជើងឯកសារទាំងអស់ (កោសលុបតាមការចាំបាច់)។

សូមអង្គជំនុំជម្រះមេត្តាទទួលនូវក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ៣ ខែ តុលា ឆ្នាំ ២០១១ | ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |